វិទ្យុ / សំឡេងជំនាន់ថ្មី

# ការសិក្សាជាកត្តាចាំបាច់សម្រាប់ដោះស្រាយវិវាទរវាងកម្មករនិងនិយោជក

បោះពុម្ព ចែករំលែក




លោក សុខ ឡោ និស្សិតថ្នាក់អនុបណ្ឌិតច្បាប់កម្មវិធីច្បាប់ថ្នាក់ក្រោយឧត្តមសិក្សានៃសាលាច្បាប់សាកលវិទ្យាល័យហាវើដ (Harvard University) បានចូលជាភ្ញៀវនៅក្នុងកម្មវិធីសំឡេងជំនាន់ថ្មី (ហេឡូវីអូអេ) ដើម្បីពិភាក្សាអំពីការកែលម្អស្ថិរភាពទំនាក់ទំនងវិជ្ជាជីវៈសម្រាប់ការរីកចម្រើនរួមគ្នារបស់កម្ពុជា។ (រូបថតផ្តល់ឲ្យដោយ សុខ ឡោ)

អ៊ឹម សុធារិទ្ធ

21 តុលា 2014

Tweet 2

Recommend Share 37

g+1 0

Pin it

វ៉ាស៊ីនតោន—បច្ចុប្បន្ននេះកម្ពុជាមិនទាន់មានការសិក្សាណាស្តីអំពីប្រាក់ឈ្នួលអប្បបរិមាដែលអាចទទួលយកបានដោយភាគីទាំងសងខាងទេ។ នេះបើតាមសម្តីរបស់លោក សុខ ឡោ ដែលបច្ចុប្បន្នជានិស្សិតអនុបណ្ឌិច្បាប់នៃសាកលវិទ្យាល័យ Harvard សហរដ្ឋអាមេរិក ថ្លែងនៅក្នុងកម្មវិធីសំឡេងជំនាន់ថ្មីរបស់វីអូអេកាលពីយប់ថ្ងៃច័ន្ទទី២០ ខែតុលា ឆ្នាំ២០១៤។ (ចុចស្តាប់កម្មវិធីទាំងស្រុង)

លោកថ្លែងថា៖ «យើងត្រូវមានការសិក្សាមួយដែលទទួលស្គាល់ដោយភាគីទាំងសងខាងដើម្បីកំណត់មើលថា តើកម្រិតត្រឹមណាដែលជាកម្រិតដែលអាចទទួលយកបាន។ ហើយការសិក្សានោះគួរតែដាក់កង្វល់ទាំងអស់របស់ភាគីទាំងអស់នៅលើតុ។ ឧទាហរណ៍ទី១ ទាក់ទងនឹងលទ្ធភាពនៃការផលិត។ ទី២តើមានគិតអំពីការប្រកួតប្រជែងក្នុងទីផ្សារតំបន់ឬទីផ្សារអន្តរជាតិដែរឬទេ។ បន្ទាប់មកថា តើមានដែលគិតអំពីថ្លៃចាយវាយរបស់កម្មករដែរឬទេ។ និងប្រាក់ចំណេញរបស់អ្នកវិនិយោគត្រូវបានយកមកគិតក្នុងកម្រិតណា?»។

## អត្ថបទព័ត៌មានទាក់ទង

- រដ្ឋាភិបាលគ្រោងបង្កើតក្រុមការងារចរចាប្រាក់ខែកម្មករនៅសប្តាហ៍ក្រោយ
- ប្រវត្តិសាស្ត្រជាមេរៀនសម្រាប់អភិវឌ្ឍជាតិ
- មីក្រុបវិទ្យាជួយព្យាបាលជំងឺមនុស្សជាតិ
- និស្សិត លី ស៊ីវហួង មានសុទិដ្ឋិនិយមចំពោះវិស័យសុខាភិបាលនៅកម្ពុជា
- ប្រព័ន្ធគណនេយ្យនិងសវនកម្មល្អសំខាន់សម្រាប់ការអភិវឌ្ឍ

មេធាវីការពារក្តីមេដឹកនាំខ្មែរក្រហមពន្យល់អំពីពហិការសវនាការ




ក្រុមមេធាវីការពារក្តីមេដឹកនាំខ្មែរក្រហមដើរចេញពីសវនាការ

អង់គ្លេសជាមួយម៉ានីនិងម៉ូរី

Face the Music ទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់ខ្លួន

ផ្សេងទៀត»

ការកែលម្អស្ថិរភាពទំនាក់ទំនងវិជ្ជាជីវៈសម្រាប់ការរីកចម្រើនរួមគ្នារបស់កម្ពុជា

លោក សុខ ឡោ បានថ្លែងនៅក្នុងកម្មវិធីសំឡេងជំនាន់ថ្មីថា ផ្នែកមួយនៃយុទ្ធសាស្ត្រក្នុងកាត់បន្ថយភាពក្រីក្រនិងជំរុញឲ្យមានការរីកចម្រើន គឺការព្យាយាមលើកទឹកចិត្តវិនិយោគិនបរទេសឲ្យចូលមកវិនិយោគនៅក្នុងប្រទេស។ ថ្លែងនៅក្នុងកម្មវិធីសំឡេងជំនាន់ថ្មីរបស់វីអូអេ លោក សុខ ឡោ បញ្ជាក់ថា កត្តាសំខាន់មួយសម្រាប់ទាក់ទាញវិនិយោគិនបរទេសឲ្យចូលមកកម្ពុជានោះគឺ តម្លៃកម្លាំងពលកម្មកម្ពុជានៅមានតម្លៃទាបបើប្រៀបធៀបនឹងប្រទេសផ្សេងៗ។ តម្លៃទាបនៃពលកម្មក្នុងវិស័យកាត់ដេរបានទាក់ទាញវិនិយោគ។ លោកថា វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងបានផ្តល់ការងារបានប្រមាណ៦សែននាក់។

លោក សុខ ឡោ និយាយថា អស្ថិរភាពនៃទំនាក់ទំនងវិជ្ជាជីវៈរវាងសហជីពនិងនិយោជកបណ្តាលមកពីការពិភាក្សាដែលមានភាពចម្រូងចម្រាសលើកម្រិតប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យកាត់ដេរសម្លៀកបំពាក់និងដេរស្បែកជើង ការបំពានបទដ្ឋានការងារ និងកូដកម្មខុសច្បាប់ ដែលមិនត្រឹមតែរំខានដល់វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងប៉ុណ្ណោះទេ តែថែមទាំងជះឥទ្ធិពលជាអវិជ្ជមានដល់វិស័យឧស្សាហកម្មផ្សេងៗទៀតនៅក្នុងប្រទេស។

លោក សុខ ឡោ បានប្រាប់កម្មវិធីសំឡេងជំនាន់ថ្មីថា ទំនាក់ទំនងវិជ្ជាជីវៈគឺជាបញ្ហាស្មុគ្រស្មាញ តែចំបាច់ត្រូវយកមកពិភាក្សាដើម្បីដោះស្រាយវិវាទ។

លោក សុខ ឡោ បញ្ជាក់ថា ការចរចាប្រចាំឆ្នាំស្តីអំពីប្រាក់ឈ្នួលមានចំណុចវិជ្ជមាននិងអវិជ្ជមាន។

«វាអាចបើកឱកាសឲ្យខាងកម្មករបានប្រាក់ខែឡើងជារៀងរាល់ឆ្នាំ។ តែដោយសារតែប្រព័ន្ធរបស់យើងអត់មានស្តង់ដាច្បាស់លាស់សម្រាប់ការចរចា ពេលចរចាម្តងៗ ភាគីទាំងសងខាងភ័យទាំងអស់គ្នា។ ភ័យនោះគឺថា តើការចរចានោះអាចនាំឲ្យមានការតវ៉ាតាមផ្លូវថ្នល់ដែលនាំឲ្យស្ទះសង្វាក់ផលិតកម្ម»។

លោក សុខ ឡោ ថ្លែងថា ជាទូទៅការដោះស្រាយវិវាទរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានទទួលស្គាល់ច្រើននិងមានការគោរពប្រព័ន្ធនៃស្ថាប័ននេះ។ លោក សុខ ឡោ ថា ឆ្នាំ២០១៤នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបានជិត៣០០សំណុំរឿងហើយ ដែលតួលេខនេះបញ្ជាក់ថា មានការអនុវត្តនិងប្រើប្រាស់សេវារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលច្រើនសម្រាប់ដោះស្រាយវិវាទ៕

បោះពុម្ព ចែករំលែក

Tweet 2 Recommend Share 37 +1 0 Pin it

Find us on Facebook
VOA Khmer
Like You like this.
You and 1,037,105 others like VOA Khmer.
Facebook social plugin

វីអូអេ ផ្សាយតាម ទូរទស្សន៍

សាលារៀននៅអ៊ុយក្រែនចាប់ផ្តើមដោយមានការបរិច្ចាគដល់កងទ័ព
វីដេអូផ្សេងទៀត

សេវាទទួលព័ត៌មាន Podcast RSS ព្រឹត្តិប័ត្រតាមអ៊ីម៉េល ទូរស័ព្ទ

ព័ត៌មាន
កម្ពុជា
អាស៊ីអាគ្នេយ៍
អន្តរជាតិ
អាមេរិក
នយោបាយ
សិទ្ធិមនុស្ស
ខ្មែរក្រហម
សេដ្ឋកិច្ច

ស្តាប់វិទ្យុ
ព័ត៌មានពេលព្រឹក
ព័ត៌មានពេលរាត្រី
ហេឡូវីអូអេ
សំឡេងជំនាន់ថ្មី
សំឡេងយុវជន
ស្តាប់ Podcasts
រៀនភាសាអង់គ្លេស

មើលទូរទស្សន៍ វីដេអូ
វ៉ាស៊ីនតោនសប្តាហ៍នេះ
វ៉ាស៊ីនតោនថ្ងៃនេះ
វីដេអូខ្មែរ
នាទីស្វែងយល់
សំឡេងឌីជីថល
សេដ្ឋកិច្ចអាមេរិក
វីអូអេវិទ្យាសាស្ត្រ
មើល Podcast

បណ្តាញសង្គម
Facebook
Twitter
SoundCloud
AngkorOne
ទទួលព័ត៌មានតាម
ទូរស័ព្ទ
បណ្តាញ RSS

គេហទំព័រផ្សេងទៀត
Broadcasting Board of Governors
Inside VOA (Pressroom)
VOA English
Terms of Use/Privacy Notice
វិទ្យុអាស៊ីសេរី